# ធ្វើកិច្ចការដោយអស់ពីសេចក្ដីព្យាយាម

*ប្រធាន ហិនរី ប៊ី អាវរីង*
*ទីប្រឹក្សាទីមួយ នៅក្នុងគណៈប្រធានទីមួយ*

បងប្អូនប្រុស ខ្ញុំមានអំណរគុណដើម្បីនៅជាមួយនឹងអ្នករាល់គ្នានាយប់នេះ។ ហើយខ្ញុំមានចិត្តរាបសាអំពីអ្វីដែលខ្ញុំដឹង អំពីការបំរើបព្វជិតភាពដោយស្មោះត្រង់របស់អ្នក។ ខ្ញុំនិយាយទៅកាន់អ្នកនៅយប់នេះ អំពីភាពឧស្សាហ៍ព្យាយាម នៅក្នុងការបំរើរបស់ព្រះអម្ចាស់។ បទពិសោធន៍ថ្មីៗនេះ បាននាំឱ្យខ្ញុំជ្រើសរើសយកប្រធានបទនេះ។

បទពិសោធន៍មួយក្នុងពេលថ្មីៗនេះ គឺជាការសិក្សាដោយប្រុងប្រយ័ត្នរបស់ខ្ញុំ អំពីកូនសៀវភៅថ្មីដ៏អស្ចារ្យសម្រាប់ បព្វជិតភាពអើរ៉ុន។ វាមានចំណងជើងថា *កាតព្វកិច្ចចំពោះព្រះ ។* នៅពេលខ្ញុំអាន និងពិចារណា អំពីអ្វីដែលកូន សៀវភៅនេះ រំពឹងចង់ឱ្យយុវជនធ្វើ និងប្រែក្លាយ ខ្ញុំបានដឹងច្បាស់ថា វាគឺជាការពិពណ៌នា អំពីអ្វី ដែលប្រធាន ព្រិកហាំ យ៉ង់ បានសន្យាចំពោះអ្នកកាន់បព្វជិតភាព ដែលឧស្សាហ៍ព្យាយាមនៅពេញមួយជីវិតរបស់គាត់ថា៖

«បុគ្គលម្នាក់ៗ ដែលកាន់បព្វជិតភាព ហើយបន្តស្មោះត្រង់នៅក្នុងការហៅរបស់គាត់ ដែលបន្តរីករាយនឹងការធ្វើនូវរឿង ទាំងឡាយដែលព្រះតម្រូវឱ្យគាត់ធ្វើ និងបន្តនៅពេញមួយជីវិត នៅក្នុងការធ្វើរាល់កាតព្វកិច្ចនឹងទទួលបានសម្រាប់ខ្លួន គាត់ មិនត្រឹមតែឯកសិទ្ធិក្នុងការទទួលប៉ុណ្ណោះទេ ប៉ុន្តែជាចំណេះដឹងអំពីរបៀបដើម្បីទទួលនូវរឿងទាំងឡាយ របស់ព្រះ ដែលគាត់អាចស្គាល់អំពីគំនិតនៃព្រះជាបន្តបន្ទាប់»។ 1

ទើបតែពីរបីសប្ដាហ៍កន្លងទៅនេះ ខ្ញុំបានមើលឃើញឌីកុនថ្មីម្នាក់ បានចាប់ផ្ដើមនៅលើផ្លូវនៃភាពឧស្សាហ៍ព្យាយាមនោះ។ ឪពុករបស់គាត់បានបង្ហាញដល់ខ្ញុំ នូវរូបប្លង់ដែលកូនប្រុសរបស់គាត់បានបង្កើត ដែលបង្ហាញពីជួរទាំងអស់ នៅក្នុងសាលាជំនុំរបស់ពួកគេ មានលេខមួយសម្រាប់ឌីកុនម្នាក់ៗ ដែលនឹងចាត់ឱ្យចែកសាក្រាម៉ង់ និងផ្លូវសម្រាប់ឌីកុន ម្នាក់ៗដើរនៅក្នុងសាលាជំនុំ ដើម្បីបំរើសាក្រាម៉ង់ទៅដល់សមាជិក។ ឪពុកគាត់ និងខ្ញុំបានញញឹម ហើយគិតថា គាត់ជាក្មេងប្រុសម្នាក់ ដែលរៀបចំផែនការ ដើម្បីប្រាកដថា គាត់នឹងធ្វើការបំរើនៅក្នុងបព្វជិតភាពរបស់វាដោយ ជោគជ័យ ដោយមិនបាច់មានការសុំឱ្យធ្វើនោះទេ។

ខ្ញុំបានទទួលស្គាល់នូវភាពឧស្សាហ៍ព្យាយាមរបស់គាត់ ជាគំរូមកពីកូនសៀវភៅ *កាតព្វកិច្ចចំពោះព្រះ* ថ្មី។ គឺត្រូវរៀននូវ អ្វី ដែលព្រះអម្ចាស់រំពឹងចង់បានពីអ្នក រៀបចំផែនការដើម្បីធ្វើកិច្ចការនោះ អនុវត្តផែនការអ្នកដោយឧស្សាហ៍ព្យាយាម ហើយបន្ទាប់មក ចែកចាយជាមួយនឹងអ្នកដទៃអំពីរបៀបដែលបទពិសោធន៍របស់អ្នក ផ្លាស់ប្ដូរអ្នក និងប្រទានពរដល់អ្នកដទៃ។

ក្មេងប្រុសឌីកុនដែលបានធ្វើប្លង់នោះ ធ្វើវាដើម្បីឱ្យប្រាកដថា គាត់នឹងអាចធ្វើនូវអ្វីដែលព្រះអម្ចាស់ បាន ហៅឱ្យគាត់ ធ្វើ។ នៅពេលចាប់ផ្តើមការបំរើបព្វជិតភាពរបស់គាត់ ព្រះអម្ចាស់បានបង្រៀនគាត់ឱ្យរីករាយ នៅក្នុងការ «ធ្វើនូវរឿង ទាំងឡាយដែលព្រះតម្រូវឱ្យគាត់ធ្វើ» ជាបន្តបន្ទាប់។ 2

បទពិសោធន៍មួយទៀត ដែលនាំខ្ញុំឱ្យនិយាយអំពីភាពឧស្សាហ៍ព្យាយាម នៅយប់នេះ គឺការមើលទៅបុរស ម្នាក់ដែលជិតនឹងបញ្ចប់ការបំរើបព្វជិតភាពរបស់គាត់នៅក្នុងជីវិតនេះ។ គាត់បានធ្វើជាប៊ីស្សពពីរដង។ ការហៅទីមួយរបស់គាត់ គឺឱ្យធ្វើជាប៊ីស្សពតាំងពីគាត់នៅក្មេង វាមានរយៈពេលជាច្រើនឆ្នាំ មុនពេលដែល ខ្ញុំបានជួបគាត់។ ឥឡូវនេះ គាត់ចាស់ ហើយ គាត់ត្រូវបានដោះលែងសម្រាប់ការហៅឱ្យធ្វើជាប៊ីស្សពលើក ទីពីរ។ ការកំណត់ចំពោះសុខភាពរាងកាយរបស់គាត់ កំពុងតែបង្កើនឡើង ដែលធ្វើឱ្យការបំរើបព្វជិតភាព ទាំងអស់មានការលំបាក។

ប៉ុន្តែ គាត់មានផែនការ ដើម្បីធ្វើកិច្ចការដោយការព្យាយាម។ គាត់បានមកអង្គុយនៅរាល់ថ្ងៃអាទិត្យ នៅ ពេលគាត់អាច ទៅព្រះវិហារបាន គាត់អង្គុយនៅជួរក្រោយគេ ជិតមាត់ទ្វារ ជាកន្លែងដែលមនុស្សជាច្រើន ដើរចូលមកក្នុង ការប្រជុំសាក្រាម៉ង់។ គាត់ទៅទីនោះឱ្យបានមុន ដើម្បីប្រាកដថាមានកៅអីសម្រាប់គាត់។ មនុស្សម្នាក់ៗដែលមកដល់ អាចមើលឃើញទឹកមុខនៃក្តីស្រឡាញ់ និងស្វាគមន៍របស់គាត់តាមរបៀបដូច គ្នា កាលដែលគាត់អង្គុយនៅលើវេទិការ ក្នុងនាមជាប៊ីស្សពរបស់ពួកគេ។ ឥទ្ធិពលរបស់គាត់ បានធ្វើឱ្យ យើងមានភាពកក់ក្តៅ និងលើកដំកើង ដោយសារតែយើងបានដឹងអំពីតម្លៃ ដែលគាត់បានបង់ថ្លៃចំពោះ ការបំរើ។ កិច្ចការរបស់គាត់ក្នុងនាមជាប៊ីស្សពត្រូវបានបញ្ចប់ តែការបំរើបព្វជិតភាពរបស់គាត់ មិនបាន បញ្ចប់ទេ។

យើងបានមើលឃើញគំរូដូចគ្នានេះរបស់ពួកអ្នកបំរើបព្វជិតភាពដ៏មហិមា។ នៅយប់នេះ ខ្ញុំនឹងព្យាយាម ប្រាប់ដល់អ្នករាល់គ្នា អំពីអ្វីដែលខ្ញុំបានរៀនមកពីពួកគាត់។ វាចាប់ផ្តើមជាមួយនឹងការរៀនរបស់ពួកគាត់ ដើម្បីស្គាល់ថាពួកគាត់កំពុងបំរើនរណា ហើយសម្រាប់គោលបំណងអ្វី។ នៅពេលពួកគាត់ទទួលបាន ចំណេះដឹងនេះចាក់ឫសក្នុងបេះដូងពួកគាត់ហើយ នោះវាធ្វើឱ្យពួកគាត់ធ្វើជាអ្នកបំរើកាន់តែល្អប្រសើរ។

ដំបូង ខ្ញុំនឹងនិយាយចំៗទៅកាន់យុវជននៃបព្វជិតភាពអើរ៉ុន។ អ្នករាល់គ្នា នឹងកាន់តែឧស្សាហ៍ព្យាយាម នៅពេលអ្នក ទទួលអារម្មណ៍ដឹងអំពីទំហំនៃទំនុកចិត្ត ដែលព្រះបានមានចំពោះអ្នក។ មានសារលិខិតមួយ មកពីគណៈប្រធានទីមួយ សម្រាប់អ្នករាល់គ្នា នៅក្នុងកូនសៀវភៅ *កាតព្វកិច្ចចំពោះព្រះ។*

«ព្រះវរបិតាសួគ៌ មានការទុកចិត្ត និងទំនុកចិត្តដ៏មហិមាទៅលើអ្នក ហើយមានបេសកកម្មដ៏សំខាន់មួយ សម្រាប់អ្នកបំពេញ។ ទ្រង់នឹងជួយអ្នក នៅពេលអ្នកបែរមករកទ្រង់នៅក្នុងការអធិស្ឋាន។ ចូរស្តាប់ ការបំផុសគំនិត ពី ព្រះវិញ្ញាណ។ គោរពព្រះបញ្ញត្តិ និងរក្សាសេចក្តីសញ្ញា ដែលអ្នកបានធ្វើ»។ 3

យ៉ូហាន បាទីស្ទ បានត្រឡប់មកផែនដីវិញ ដើម្បីស្ដារបព្វជិតភាពដែលអ្នកកាន់នេះ។ គាត់កាន់កូនសោទាំងឡាយនៃបព្វជិតភាពអើរ៉ុន។ គាត់គឺជាយ៉ូហាន ដែលព្រះយេស៊ូវបានទៅរកដើម្បីទទួលបុណ្យជ្រមុជទឹក។ យ៉ូហាន បានដឹងថា នរណាបានហៅគាត់។ គាត់បានទូលទៅព្រះអម្ចាស់ថា «ទូលបង្គំដែលត្រូវទទួលបុណ្យជ្រមុជពីទ្រង់វិញទៅតើ»។ 4

យ៉ូហានបានដឹងថា បព្វជិតភាពអើរ៉ុន កាន់កូនសោទាំងឡាយនៃការបំរើរបស់ពួកទេវតា និងនៃដំណឹងល្អនៃការប្រែចិត្ត និងនៃបុណ្យជ្រមុជទឹក ដោយការពន្លិចសម្រាប់ការផ្ដាច់បាប នៅពេលព្រះអម្ចាស់បានបញ្ជូនគាត់ឱ្យតែងតាំងដល់ យ៉ូសែប ស្ម៊ីធ និងអូលីវើរ ខៅឌឺរី នៅថ្ងៃទី 15 ខែ ឧសភា ឆ្នាំ 1829 ។ គាត់បានដឹងថានរណាបានហៅគាត់ ហើយគាត់ត្រូវបានបញ្ជូនឱ្យមក សម្រាប់គោលបំណងដ៏រុងរឿងជាយ៉ាងណា។

ការហៅបព្វជិតភាពរបស់អ្នក អនុញ្ញាតឱ្យអ្នកផ្ដល់សាក្រាម៉ង់នៃការលៀងបរិភោគរបស់ព្រះអម្ចាស់ ទៅដល់សមាជិក ក្នុងសាសនាចក្ររបស់ទ្រង់នាសព្វថ្ងៃនេះ។ នោះគឺជាអំណាច ដែលព្រះអង្គសង្គ្រោះបានប្រទានដល់ពួកសាវកដប់ពីរនាក់ នៅក្នុងការបំរើក្នុងជីវិតរមែងស្លាប់របស់ទ្រង់។ ទ្រង់បានធ្វើដូចគ្នានេះម្ដងទៀត នៅពេលទ្រង់បានហៅពួកសិស្សដប់ពីរនាក់ បន្ទាប់ពីការរស់ឡើងវិញរបស់ទ្រង់ ដើម្បីដឹកនាំសាសនាចក្ររបស់ទ្រង់។

ព្រះអម្ចាស់ផ្ទាល់ បានពិពណ៌នានៅក្នុងព្រះគម្ពីរមរមន ដែលបានផ្ដល់ជានិមិត្តរូបនៃការពលិកម្មដ៏ធំបំផុតរបស់ទ្រង់ ហើយបានបំរើដល់ប្រជាជន។ ចូរគិតអំពីទ្រង់ និងគិតអំពីរបៀប ដែលទ្រង់គោរពដល់អ្នក នៅពេលអ្នកធ្វើការបំរើ បព្វជិតភាពរបស់អ្នក។ នៅពេលអ្នកចងចាំអំពីទ្រង់ នោះអ្នកនឹងត្រូវបានប្ដេជ្ញាចិត្ត ដើម្បីធ្វើការបំរើនោះ ឱ្យបានច្រើនដូចជាទ្រង់ តាមដែលអ្នកអាចធ្វើបាន ឱ្យបានល្អ និងស្មោះត្រង់ដូចដែលទ្រង់បានធ្វើ។ 5

នោះវាអាចក្លាយជាគំរូមួយ នៅក្នុងជីវិតរបស់អ្នក ដែលនឹងបង្កើនអំណាចរបស់អ្នកឱ្យមានភាពឧស្សាហ៍ នៅក្នុងគ្រប់ការបំរើបព្វជិតភាព ដែលព្រះអម្ចាស់កំពុងតែរៀបចំអ្នក ហើយដែលទ្រង់នឹងហៅអ្នក។ ការប្ដេជ្ញាចិត្តនោះនឹងជួយអ្នករៀបចំខ្លួនដើម្បីទទួលបព្វជិតភាពមិលគីស្សាដែក ដែលត្រូវបានហៅពីបុរាណថាជា «បព្វជិតភាពដ៏បរិសុទ្ធ តាម របៀបនៃព្រះរាជបុត្រានៃព្រះ»។ 6

ឥឡូវនេះ ខ្ញុំចង់និយាយទៅកាន់អ្នកទាំងឡាយណាដែលត្រូវបានហៅ និងផ្ដល់កិត្តិយសឱ្យបំរើនៅក្នុងបព្វជិតភាពមិលគីស្សាដែក។ ក៏ដូចជាបព្វជិតភាពអើរ៉ុនផងដែរ បព្វជិតភាពមិលគីស្សាដែក គឺត្រូវបានទុកចិត្តកាន់តែខ្លាំង ដើម្បីធ្វើ នូវអ្វីដែលព្រះអម្ចាស់ នឹងធ្វើ។ វាគឺជាការអញ្ជើញមួយ ដើម្បីឱ្យប្រែក្លាយដូចជា

ទ្រង់។ នេះគឺជាការសន្យារបស់ទ្រង់៖

«ត្បិតអស់អ្នកណាដែលស្មោះត្រង់ ក្នុងកាលបានបព្វជិតភាពទាំងពីរនេះ ដែលយើងបានពោលដល់ ហើយបានដំកើងការហៅរបស់ខ្លួន នោះត្រូវបានញែកជាបរិសុទ្ធ ដោយសារព្រះវិញ្ញាណចំពោះការសាងរូបកាយរបស់ពួកគេជាថ្មី។ ពួកគេត្រឡប់ជាកូនប្រុសនៃលោកម៉ូសេ និងលោកអើរ៉ុន ហើយជាពូជនៃលោកអ័ប្រាហាំ និងជាសាសនាចក្រ និងនគរ និងជាពួករើសតាំងនៃព្រះ។ ហើយអស់អ្នកណាដែលទទួលបព្វជិតភាពនេះ ឈ្មោះថាទទួលយើងដែរ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ត្បិតអ្នកណាដែលទទួលពួកអ្នកបំរើរបស់យើង ឈ្មោះថាទទួលយើងដែរ។ ហើយអ្នកណាដែលទទួលយើង ឈ្មោះថាទទួលព្រះវរបិតាយើងដែរ ហើយអ្នកណាដែលទទួលព្រះវរបិតាយើង ឈ្មោះថាទទួលនគររបស់ព្រះវរបិតាយើងដែរ ហេតុដូច្នេះហើយ គ្រប់អ្វីៗ ទាំងអស់ ដែលព្រះវរបិតាមាន នោះនឹងត្រូវបានប្រទានដល់អ្នកនោះដែរ»។ 7

មានគំរូមួយ ដែលអ្នកកាន់បព្វជិតភាពទាំងអស់ ត្រូវបានដំកើងឡើងទៅដល់ពរជ័យដ៏រុងរឿងនោះ។ មានកន្លែងមួយ នៅក្នុងព្រះគម្ពីរ ដែលព្រះអម្ចាស់បានប្រទានគំរូសម្រាប់យើង គឺនៅក្នុងកណ្ឌទី 107 នៃគោលលទ្ធិ និងសេចក្ដីសញ្ញា៖

«ហេតុដូច្នោះហើយ នៅពេលឥឡូវនេះ ចូរឱ្យមនុស្សគ្រប់រូបរៀនពីភារកិច្ចរបស់ខ្លួន ហើយឱ្យប្រតិបត្តិក្នុងតំណែង ដែលខ្លួនត្រូវបានតាំងឡើង ដោយសេចក្តីឧស្សាហ៍គ្រប់ជំពូក។ អ្នកណាដែលខ្ជិលច្រអូសមិនត្រូវបានរាប់ថាសមនឹងឈរឡើយ ហើយអ្នកណាដែលមិនរៀនពីភារកិច្ចរបស់ខ្លួន ហើយ បង្ហាញខ្លួនថា ពុំបានទទួលការអនុមតិទេ នោះមិនត្រូវបានរាប់ថាសមនឹងឈរឡើយ»។ គឺដូច្នោះមែន។ អាម៉ែន។ 8

យើងត្រូវរៀនពីភារកិច្ចរបស់យើងមកពីព្រះ ហើយបន្ទាប់មកយើងត្រូវ ធ្វើកិច្ចការដោយអស់ពីការព្យាយាមមិនត្រូវខ្ជិលច្រអូសឡើយ។ គំរូនេះគឺសាមញ្ញ ប៉ុន្តែមិនងាយស្រួលក្នុងការធ្វើតាមទេ។ យើងត្រូវបានរំខានដោយងាយស្រួលណាស់។ ការសិក្សាអំពីព័ត៌មានប្រចាំថ្ងៃ អាចមានចំណាប់អារម្មណ៍ជាងសៀវភៅមេរៀនបព្វជិតភាព។ ការអង្គុយសំរាកអាចនឹងមានការទាក់ទាញជាង ការណាត់ជួបទៅសួរសុខទុក្ខអ្នកទាំងឡាយដែលត្រូវការការបំរើបព្វជិតភាពរបស់យើង។

នៅពេលខ្ញុំរកឃើញថា ខ្លួនខ្ញុំកំពុងតែងាកចេញពីកាតព្វកិច្ចបព្វជិតភាពរបស់ខ្ញុំ ដោយចំណាប់អារម្មណ៍ផ្សេងៗ និងនៅពេលរូបកាយរបស់ខ្ញុំត្រូវការសំរាក ខ្ញុំលើកទឹកចិត្តដល់ខ្លួនខ្ញុំជាមួយនឹងពាក្យទាំងនេះថា៖ «សូមចងចាំអំពីទ្រង់»។ ព្រះអម្ចាស់ គឺជាគំរូនៃភាពឧស្សាហ៍ដ៏ឥតខ្ចោះរបស់យើង នៅក្នុងការបំរើបព្វជិតភាព។ ទ្រង់គឺជាអ្នកមេបញ្ជាការរបស់យើង។ ទ្រង់បានហៅយើង។ ទ្រង់បានយាងទៅមុនយើង។ ទ្រង់បានជ្រើសរើសយើង ឱ្យដើរតាមទ្រង់ ហើយនាំអ្នកដទៃ ទៅជាមួយយើងផង។

ល្ងាចនេះ ខ្ញុំចងចាំអំពីទ្រង់ ហើយវាបានប៉ះដល់ដួងចិត្តរបស់ខ្ញុំ។ នេះគឺជាយប់ថ្ងៃសៅរ៍មុនថ្ងៃអាទិត្យបុណ្យអ៊ីស្ទើរ ជាពេលដែលយើងចងចាំអំពីការរស់ឡើងវិញរបស់ទ្រង់។ ខ្ញុំចងចាំអំពីគំរូរបស់ទ្រង់នៅក្នុងថ្ងៃមុនការសុគតរបស់ទ្រង់។

ដោយក្ដីស្រឡាញ់ចំពោះព្រះវរបិតារបស់ទ្រង់ និងចំពោះយើង ទ្រង់បានអនុញ្ញាតឱ្យរូបអង្គទ្រង់ ត្រូវរងទុក្ខហួសពី សមត្ថភាពរបស់មនុស្សនៃជីវិតរមែងស្លាប់អាចធ្វើបាន។ ទ្រង់បានប្រាប់ដល់យើងអំពីអ្វីខ្លះៗ ដែលតម្រូវឱ្យមាន  ការពលិកម្មដ៏ធំបំផុតរបស់ទ្រង់នោះ។

«ត្បិតមើលចុះ យើងជាព្រះ បានរងទុក្ខនូវការទាំងនេះជំនួសមនុស្សទាំងអស់ ដើម្បីកុំឱ្យគេអាចរងទុក្ខ បើសិនជាពួកគេ ប្រែចិត្ត ប៉ុន្តែបើសិនជាពួកគេមិនព្រមប្រែចិត្តទេ នោះពួកគេត្រូវរងទុក្ខដូចជាយើងដែរ គឺជាសេចក្ដីរងទុក្ខវេទនា ដែលបណ្ដាលឱ្យយើង គឺជាព្រះដែលមហិមាលើអ្វីៗទាំងអស់ ត្រូវញ័រដោយសារតែការឈឺចាប់ ហើយត្រូវច្រួចលោហិតចេញពីគ្រប់រន្ធញើស ហើយត្រូវរងទុក្ខព្រមទាំងរូបកាយ និងវិញ្ញាណផង-- ហើយដើម្បីកុំឱ្យ យើងត្រូវផឹកពែងល្វីង ហើយរួញខ្លាច---ទោះជាយ៉ាងណាក៏ដោយ សូមព្រះវរបិតាបានសិរីល្អ ហើយយើងបានទទួលទាន និងសម្រេចការរៀបចំរបស់យើង ចំពោះកូនចៅមនុស្ស»។ 9

ព្រះអង្គសង្គ្រោះ បានប្រកាសចេញមកពីលើឈើឆ្កាង នៅកាលវ៉ារីថា៖ «ការស្រេចហើយ»។ 10 បន្ទាប់មកព្រះវិញ្ញាណរបស់ទ្រង់បានចាកចេញពីរូបកាយ រួចរូបកាយជីវិតរមែងស្លាប់របស់ទ្រង់ ត្រូវបានដាក់ទុកដោយក្ដីស្រឡាញ់ នៅក្នុងផ្នូរមួយ។ ទ្រង់បានបង្រៀនយើង នូវមេរៀនមួយ តាមរយៈអ្វីដែលទ្រង់បានធ្វើនៅក្នុងពេលបីថ្ងៃ នៅក្នុងពិភព វិញ្ញាណ មុនពេលការរស់ឡើងវិញរបស់ទ្រង់ ដែលខ្ញុំចងចាំ នៅពេលណាខ្ញុំត្រូវបានល្បួងឱ្យមានអារម្មណ៍ថា ខ្ញុំបានបញ្ចប់កិច្ចការពិបាកៗមួយចំនួននៅក្នុងការបំរើរបស់ទ្រង់ ហើយសមនឹងបានសំរាក។

គំរូរបស់ព្រះអង្គសង្គ្រោះ បានផ្ដល់ការលើកទឹកចិត្តដល់ខ្ញុំឱ្យឆ្ពោះទៅមុខ។ កិច្ចការរបស់ទ្រង់នៅក្នុងជីវិតរមែងស្លាប់ ត្រូវបានបញ្ចប់ ប៉ុន្តែទ្រង់បានចូលទៅក្នុងពិភពវិញ្ញាណ បានប្ដេជ្ញាចិត្តដើម្បីបន្តកិច្ចការដ៏រុងរឿងរបស់ទ្រង់ ដើម្បីសង្គ្រោះដល់ព្រលឹង។ ទ្រង់បានរៀបចំកិច្ចការរបស់ពួកវិញ្ញាណស្មោះត្រង់ ដើម្បីសង្គ្រោះវិញ្ញាណទាំងឡាយ ដែលអាចនៅតែ ត្រូវបានប្រទានពរដោយក្ដីមេត្តាករុណារបស់ទ្រង់ ដែលទ្រង់បានធ្វើឱ្យកើតមាន តាមរយៈពលិកម្មដង្វាយធួនរបស់ទ្រង់។

«ប៉ុន្តែមើលចុះ ពីចំណោមពួកសុចរិត នោះទ្រង់បានរៀបចំពលរបស់ទ្រង់ ហើយបានតាំងសារទូតទាំងឡាយ គឺបំពាក់ដោយអំណាច និងសិទ្ធិអំណាច ហើយបានអនុញ្ញាតឱ្យពួកគេចេញទៅ ហើយនាំពន្លឺនៃដំណឹងល្អទៅឱ្យពួកគេ ដែលនៅក្នុងសេចក្ដីងងឹត គឺទៅដល់គ្រប់អស់ទាំងវិញ្ញាណនៃមនុស្សលោក ហើយ

ដំណឹងល្អត្រូវបានផ្សាយដល់ពួកអ្នកស្លាប់តាមបែបដូច្នោះហើយ។ ហើយពួកសារទូតដែលបានរើសឡើង នោះ បានចេញទៅប្រកាសប្រាប់ពីថ្ងៃ ដែលព្រះអម្ចាស់ទ្រង់សព្វព្រះហឫទ័យ ហើយប្រកាសប្រាប់ពី ឥស្សរភាពដល់ពួកជាប់ឃុំឃាំង ដែលជាប់ចំណង គឺដល់អស់អ្នកណាដែលព្រមប្រែចិត្តពីអំពើបាបទាំង ឡាយរបស់ខ្លួន ហើយទទួលបានដំណឹងល្អ»។ 11

នៅពេលណា យើងចងចាំទ្រង់ នោះវាកាន់តែងាយស្រួលដើម្បីតទល់នឹងការល្បួងក្នុងការសំរាកពីកិច្ចការ បព្វជិតភាពរបស់យើង។ យើងត្រូវតែចងចាំទ្រង់នៅថ្ងៃនេះ ដោយសារតែយើងនៅទីនេះដើម្បីរៀនអំពី កាតព្វកិច្ចរបស់យើង ប្ដេជ្ញាចិត្តដើម្បីធ្វើនូវអ្វីដែលយើងបានចុះសេចក្ដីសញ្ញាថានឹងធ្វើ ដោយឧស្សាហ៍ ព្យាយាមទាំងអស់។ ហើយដោយសារតែ គំរូរបស់ទ្រង់ នោះយើងនឹងប្រកាន់ខ្ជាប់ដរាបដល់ចុងបំផុតនៃ កិច្ចការ ដែលទ្រង់បានប្រគល់មកឱ្យយើងនៅក្នុងជីវិតនេះ ហើយតាំងចិត្តដើម្បីធ្វើតាមឆន្ទៈរបស់ព្រះវរបិតា របស់ទ្រង់ជារៀងរហូត ដូចដែលទ្រង់បានតាំងចិត្ត ហើយនៅតែតាំង ចិត្ត។

នេះគឺជាសាសនាចក្ររបស់ព្រះអម្ចាស់។ ទ្រង់បានហៅយើង ហើយទុកចិត្តលើយើង ទោះបីជាយើងទន់ ខ្សោយ ព្រោះទ្រង់បានដឹងរួចហើយ។ ទ្រង់បានដឹងអំពីការសាកល្បងដែលយើងនឹងជួបប្រទះ។ តាមរយៈ ការបំរើដោយស្មោះ ត្រង់ និងតាមរយៈដង្វាយធួនរបស់ទ្រង់ នោះយើងអាចរៀនចង់ធ្វើនូវអ្វីដែលទ្រង់ចង់ ឱ្យយើងធ្វើ ហើយរៀននូវអ្វីដែល យើងត្រូវតែធ្វើ ដើម្បីប្រទានពរដល់អ្នកទាំងឡាយដែលយើងបំរើដោយ នូវព្រះនាមទ្រង់។ នៅពេលយើងបំរើទ្រង់ រយៈពេលយូរល្មម ហើយដោយក្ដីឧស្សាហ៍ព្យាយាម នោះយើង នឹងផ្លាស់ប្ដូរ។ យើងអាចប្រែក្លាយជាបន្តបន្ទាប់ កាន់តែដូចជាទ្រង់។

ខ្ញុំបានមើលឃើញភស្ដុងតាងនៃអព្ភូតហេតុនោះ នៅក្នុងជីវិតរបស់ពួកអ្នកបំរើទ្រង់។ ខ្ញុំបានមើលឃើញវា កាលពីប៉ុន្មាន សប្ដាហ៍កន្លងទៅ នៅក្នុងបន្ទប់ទទួលភ្ញៀវរបស់អ្នកកាន់បព្វជិតភាពស្មោះត្រង់ម្នាក់។

ខ្ញុំបានស្គាល់គាត់ ក្នុងនាមជាឪកុន ជាឪពុក ជាប៊ីស្សព និងជាសមាជិកនៃគណៈប្រធានស្ដេកម្នាក់។ ខ្ញុំបាន សង្កេតមើល អស់ជាច្រើនទស្សវត្សរ៍នូវការឧស្សាហ៍ព្យាយាមរបស់គាត់ នៅក្នុងការបំរើដល់កូនចៅរបស់ ព្រះ ជាមួយនឹងបព្វជិតភាពរបស់គាត់។

គ្រួសាររបស់គាត់ បានមកជួបជុំគ្នានៅជុំវិញគាត់ក្នុងបន្ទប់ទទួលភ្ញៀវ។ គាត់ញញឹម ស្លៀកពាក់សំលៀក បំពាក់ពណ៌ស និងចងក្រវ៉ាត់ក។ ខ្ញុំមានការភ្ញាក់ផ្អើល ដោយសារខ្ញុំនៅទីនោះ ពីព្រោះខ្ញុំត្រូវបានប្រាប់ថា គាត់ស្ថិតនៅក្នុងការព្យាបាល ខាងពេទ្យយ៉ាងឈឺចាប់ ដែលគាត់មិនទាន់បានជាសះស្បើយនៅឡើយ។

គាត់បានស្វាគមន៍ខ្ញុំ ដូចដែលគាត់ត្រូវស្វាគមន៍ដល់អ្នកមកលេងដទៃទៀតរាប់រយនាក់ អស់រយៈពេល ពេញមួយជីវិតនៃការបំរើបព្វជិតភាព។ ខ្ញុំបានមកជួយគាត់នៅក្នុងការសាកល្បងដែលគាត់បានប្រឈម

មុខ ប៉ុន្តែជាញឹកញាប់ណាស់ ដូចដែលបានកើតឡើងនៅក្នុងការបំរើបព្វជិតភាព គឺខ្ញុំត្រូវបានជួយ និងត្រូវបានរៀនមកវិញ។

យើងបានអង្គុយនិយាយគ្នាលេងដោយរីករាយ។ គាត់បានប្រាប់ខ្ញុំអំពីរបៀប ដែលឪពុករបស់គាត់ បានមើលថែដល់ ម្ដាយរបស់ខ្ញុំ នៅពេលគាត់ហៀបនឹងស្លាប់។ ខ្ញុំមិនបានដឹងរឿងនោះសោះ។ ពេលនោះខ្ញុំបានដឹងយ៉ាងច្បាស់ថា គាត់បានរៀនកាលពីនៅក្មេងមកពីឪពុករបស់គាត់ អំពីរបៀបដើម្បីបំរើដល់អ្នកដទៃ។ គំនិតនោះ បានធ្វើឱ្យខ្ញុំមាន អំណរគុណចំពោះពេលវេលា ដែលខ្ញុំបាននាំកូនប្រុសតូចរបស់ខ្ញុំទៅជាមួយខ្ញុំ ក្នុងការចុះសួរសុខទុក្ខខាងបព្វជិតភាព ដើម្បីលួងលោមចិត្ត និងប្រសិទ្ធពរ។

បន្ទាប់ពីរយៈពេលពីរបីនាទីក្រោយមក គាត់បានសួរដោយស្ងាត់ៗថា «តើសមរម្យទេ បើខ្ញុំសុំឱ្យលោកផ្ដល់ការប្រសិទ្ធពរមួយដល់ខ្ញុំនោះ?» អតីតប្រធានស្តេករបស់គាត់ ព្រមទាំងអ្នកដែលគាត់បានបំរើអស់រយៈពេលជាច្រើនឆ្នាំបានចាក់ប្រេង តាំងដែលបានឧទ្ទិសលើក្បាលគាត់ ដោយអំណាចបព្វជិតភាពមិលគីស្សាដែក។

នៅពេលខ្ញុំផ្សាភ្ជាប់ការប្រសិទ្ធពរជាមួយនឹងការសន្យាទាំងឡាយ ខ្ញុំបានរៀនមកពីព្រះវិញ្ញាណបរិសុទ្ធយ៉ាងហោចណាស់ នូវចំណែកមួយ នៃអ្វីដែលព្រះអម្ចាស់បានធ្វើ សម្រាប់អ្នកកាន់បព្វជិតភាពស្មោះត្រង់នេះ។ គាត់ត្រូវបានស្អាត ហើយអំពើបាបរបស់គាត់ត្រូវបានលាងជំរះ។ ចរិតលក្ខណៈរបស់គាត់បានផ្លាស់ប្ដូរ ដើម្បីចង់បាននូវអ្វីដែលព្រះអង្គសង្គ្រោះ ចង់បាន។ គាត់មិនភ័យខ្លាចនឹងសេចក្តីស្លាប់ទេ។ បំណងប្រាថ្នានៃដួងចិត្តរបស់គាត់ គឺចង់រស់នៅដើម្បីផ្តល់ការបំរើដល់គ្រួសាររបស់គាត់ និងកូនចៅដទៃទៀតរបស់ព្រះវរបិតាសួគ៌ដែលត្រូវការគាត់។

ខ្ញុំបានដើរចេញទៅក្នុងយប់ងងឹត ដោយមានអំណរគុណ ដែលបានធ្វើជាសាក្សីចំពោះព្រះទ័យល្អរបស់ព្រះអម្ចាស់ ចំពោះអ្នកបំរើបព្វជិតភាពដ៏ឧស្សាហ៍ព្យាយាមដែលអាចពឹងពាក់បានរបស់ទ្រង់។ ទ្រង់បានផ្លាស់ប្រែដួងចិត្តរបស់ពួកគេ ឱ្យចង់បាននូវអ្វីដែលទ្រង់ចង់បាន ហើយធ្វើនូវអ្វីដែលទ្រង់នឹងធ្វើ។

ឥឡូវ ខ្ញុំសូមបញ្ចប់ជាមួយនឹងពាក្យទូន្មាននេះ ចំពោះអ្នកបំរើបព្វជិតភាពរបស់ព្រះអម្ចាស់។ ចូរពិចារណាឱ្យបានជ្រាលជ្រៅ និងដោយឧស្សាហ៍នៅក្នុងបទគម្ពីរទាំងឡាយ និងនៅក្នុងពាក្យសំដីរបស់ព្យាការីនៅរស់។ ប្រកាន់ខ្ជាប់នៅក្នុងការ អធិស្ឋានសុំព្រះវិញ្ញាណបរិសុទ្ធ ដើម្បីបង្ហាញដល់អ្នកនូវលក្ខណៈរបស់ព្រះ ជាព្រះវរបិតា និងព្រះរាជបុត្រាសំណប់របស់ ទ្រង់។ ទូលអង្វរសុំឱ្យព្រះវិញ្ញាណ នឹងបង្ហាញដល់អ្នកនូវអ្វីដែលព្រះអម្ចាស់ចង់ឱ្យអ្នកធ្វើ។ រៀបចំផែនការដើម្បីធ្វើវា។ សន្យានឹងទ្រង់ថានឹងគោរពតាម។ ធ្វើទង្វើដោយការតាំងចិត្ត រហូតដល់អ្នកបានធ្វើនូវអ្វីដែលទ្រង់សុំឱ្យអ្នកធ្វើ។ បន្ទាប់មក អធិស្ឋានដើម្បីថ្លែងអំណរគុណចំពោះឱកាសដើម្បីបំរើ និងដើម្បីដឹងនូវអ្វី ដែលអ្នកអាចធ្វើបន្ទាប់មកទៀត។

ខ្ញុំសូមថ្លែងទីបន្ទាល់ថា ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ របស់យើងមានព្រះជន្មរស់។ ពួកទ្រង់ត្រូវបានរស់ឡើងវិញ និងជាតួអង្គប្រកបដោយសិរីល្អ ថាទ្រង់ស្រឡាញ់យើង ហើយទតមើលមកលើយើង។ កូនសោទាំងឡាយនៃបព្វជិតភាព ត្រូវបានស្ដារឡើងវិញ ដោយសារទូតស្ថានសួគ៌មកដល់ព្យាការីយ៉ូសែប ស្ម៊ីធ។ ពួកគាត់បានបន្តនូវខ្សែដែលមិន បានផ្ដាច់បានមកដល់ប្រធាន ថូម៉ាស អេស ម៉នសុន។ កូនសោទាំងនោះ ត្រូវបានកាន់ដោយពួកសាវករស់នៅម្នាក់ៗ។

ខ្ញុំសូមបន្សល់ទុកនឹងអ្នករាល់គ្នានូវពរជ័យរបស់ខ្ញុំ ដើម្បីឱ្យអ្នកអាចដឹងដោយព្រះវិញ្ញាណនូវទំហំនៃទំនុកចិត្ត និងការសន្យាទាំងឡាយ ដែលអ្នកបានទទួល ក្នុងនាមជាអ្នកបំរើបព្វជិតភាព ដែលបានតែងតាំងនៅក្នុងសាសនាចក្រពិត របស់ព្រះអម្ចាស់។ នៅក្នុងព្រះនាមដ៏ពិសិដ្ឋរបស់ព្រះយេស៊ូវគ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

1. Discourses of Brigham Young ទំព័រ 132។

2. Ibid។

3. កូនសៀវភៅ *កាតព្វកិច្ចចំពោះព្រះ* សារលិខិតមកពីគណៈប្រធានទីមួយ ទំព័រ 5។

4. សូមមើល ម៉ាថាយ 3:14។

5. សូមមើលនីហ្វៃទី 3 20:1--9។

6. គ. និង ស. 107:3 សូមមើលផងដែរ អាលម៉ា 13:1--9។

7. គ. និង ស. 84:33--38។

8. គ. និង ស. 107:99--100។

9. គ. និង ស.19:16--19។

10. សូមមើល យ៉ូហាន 19:30។

11. គ. និង ស. 138:30--31។